# ច្បាប់បំពេញបន្ថែមទីក្រុងស្តុកខុលចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៦៧
## ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី២៨ កញ្ញា ឆ្នាំ ១៩៧៩

## មាតិកា


មាត្រា ១ : និយមន័យ

មាត្រា ២ : សន្និបាត

មាត្រា ៣ : ការិយាល័យអន្តរជាតិ

មាត្រា ៤ : ហិរញ្ញវត្ថុ

មាត្រា ៥ : វិសោធនកម្មមាត្រា២ដល់មាត្រា៥

មាត្រា ៦ : វិសោធនកម្មច្បាប់ឆ្នាំ ១៩៣៤ និងច្បាប់បន្ថែមឆ្នាំ១៩៦១

មាត្រា ៧ : វិសោធនកម្មច្បាប់ឆ្នាំ ១៩៦០

មាត្រា ៨ : ការផ្តល់សច្ចាប័ន និងការចូលជាសមាជិកនៃច្បាប់បំពេញបន្ថែម

មាត្រា ៩ : ការចូលជាធរមាននៃច្បាប់បំបែញបន្ថែម

មាត្រា ១០ : ការទទួលយកជាស្វ័យប្រវត្តិនូវបទប្បញ្ញត្តិមួយចំនួនដោយ
ប្រទេសមួយចំនួន

មាត្រា ១១ : ការចុះហត្ថលេខា ។ល។ នៃច្បាប់បំពេញបន្ថែម

មាត្រា ១២ : អន្តរប្បញ្ញត្តិ


### មាត្រា១
### [ និយមន័យ ]

ក្នុងគោលបំណងនៃច្បាប់បំពេញបន្ថែមនេះ :

“ ច្បាប់ឆ្នាំ១៩៣៤ ” សំដៅលើច្បាប់ ដែលបានចុះហត្ថលេខានៅទីក្រុងឡុង នៅថ្ងៃទី២ ខែមិថុនាឆ្នាំ១៩៣៤ នៃកិច្ចព្រមព្រៀងទីក្រុងឡាអេស្តីពីការតម្កល់ជាអន្តរជាតិនៃគំនូរឧស្សាហកម្ម។

“ ច្បាប់ឆ្នាំ១៩៦០ ” សំដៅទៅលើច្បាប់ដែលបានចុះហត្ថលេខានៅទីក្រុងឡាអេ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៦០ នៃកិច្ចព្រមព្រៀងទីក្រុងឡាអេស្តីពីការការតម្កល់ជាអន្តរជាតិនៃគំនូរឧស្សាហកម្ម ។

“ ច្បាប់បន្ថែមឆ្នាំ១៩៦១ ” សំដៅទៅលើច្បាប់ដែលបានចុះហត្ថលេខានៅទីក្រុងម៉ូណាកូ នៅថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ១៩៦១ ដែលបន្ថែមលើច្បាប់ឆ្នាំ ១៩៣៤ ។
“ អង្គការ ” សំដៅទៅលើអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ។
“ ការិយាល័យអន្តរជាតិ ” សំដៅទៅលើការិយាល័យកម្មសិទ្ធិបញ្ញាអន្តរជាតិ ។
“ អគ្គនាយក ” សំដៅទៅលើអគ្គនាយកនៃអង្គការ ។
“ សហភាពពិសេស ” សំដៅទៅលើសហភាពទីក្រុងឡាអេដែលបានបង្កើតឡើងដោយកិច្ចព្រមព្រៀងទីក្រុងឡាអេ ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ ១៩២៥ ស្តីពីការតម្កល់ជាអន្តរជាតិនៃគំនូរឧស្សាហកម្ម និងត្រូវបានរក្សាដោយច្បាប់ឆ្នាំ១៩៣៤និងច្បាប់ឆ្នាំ១៩៦០ ច្បាប់បន្ថែមឆ្នាំ១៩៦១ និងដោយច្បាប់បំពេញបន្ថែមនេះ ។

## មាត្រា២

### [ សន្និបាត ]

១-

ក- សហភាពពិសេសត្រូវមានសន្និបាតមួយ ដែលរួមមានប្រទេសទាំងឡាយដែលបានផ្តល់សច្ចាប័ន ឬចូលជាសមាជិកនៃច្បាប់បំពេញបន្ថែមនេះ ។

ខ- រដ្ឋាភិបាលនៃប្រទេសនីមួយៗត្រូវតំណាងដោយប្រតិភូមួយរូប ដែលអាចអមដោយប្រតិភូស្តីទី ទីប្រឹក្សា និងអ្នកជំនាញមួយចំនួន ។

គ- ការចំណាយរបស់គណៈប្រតិភូនីមួយៗ ជាបន្ទុករបស់រដ្ឋាភិបាលដែលតែងតាំងគណៈប្រតិភូនេះ ។

២-

ក- សន្និបាតត្រូវៈ

(i) ពិភាក្សារាល់បញ្ហាទាំងអស់ដែលទាក់ទងនឹងការរក្សានិងការអភិវឌ្ឍន៍នៃសហភាពពិសេស និងការអនុវត្តន៍កិច្ចព្រមព្រៀងនេះ ។

(ii) ណែនាំការិយាល័យអន្តរជាតិអំពីការរៀបចំសន្និសីទកែប្រែ ដោយពិចារណាលើមតិយោបល់នៃប្រទេសទាំងឡាយក្នុងសហភាពពិសេស ដែលមិនបានផ្តល់សច្ចាប័នឬចូលជាសមាជិកនៃច្បាប់បំពេញបន្ថែមនេះ ។

(iii) កែសម្រួលបទបញ្ជា រួមបញ្ចូលទាំងការកំណត់បរិមាណនៃកម្រៃពាក់ព័ន្ធនឹងការតម្កល់ជាអន្តរជាតិនៃគំនូរឧស្សាហកម្ម ។

(iv) ត្រួតពិនិត្យ និងអនុម័តរបាយការណ៍ និងសកម្មភាពរបស់អគ្គនាយក ដែលទាក់ទងនឹងសហភាពពិសេស ហើយណែនាំតាមការចាំបាច់ ដល់អគ្គនាយក ទាក់ទងនឹងបញ្ហានៃសមត្ថកិច្ចរបស់សហភាពពិសេស ។

(v) កំណត់កម្មវិធីនិងអនុម័តថវិកាពីរឆ្នាំម្តងនៃសហភាពពិសេស និងអនុម័តការបិទបញ្ជីគណនី ។

(vi) អនុម័តបទបញ្ញាស្តីពីហិរញ្ញវត្ថុរបស់សហភាពពិសេស ។

(vii) បង្កើតគណៈកម្មាធិការជំនាញនិងក្រុមការងារដែលចាំបាច់ដើម្បីសម្រេចគោលបំណងរបស់សហភាពពិសេស ។

(viii) កំណត់ឱ្យចូលរួមក្នុងកិច្ចប្រជុំ ក្នុងឋានៈជាអ្នកសង្កេតការណ៍ចំពោះប្រទេសដែលមិនមែនជាសមាជិកនៃសហភាពពិសេស និងអង្គការអន្តររដ្ឋាភិបាលនិងអង្គការអន្តរជាតិមិនមែនរដ្ឋាភិបាល ។

(ix) អនុម័តវិសោធនកម្មមាត្រា២ ដល់ មាត្រា៥ ។

(x) ចាត់វិធានការសមស្របផ្សេងទៀតដើម្បីសម្រេចគោលបំណងរបស់សហភាពពិសេស ។

(xi) បំពេញមុខងារផ្សេងទៀតដែលស្របតាមច្បាប់បន្ថែមនេះ ។

ខ- ចំពោះបញ្ហាដែលពាក់ព័ន្ធនឹងផលប្រយោជន៍ផងដែរ របស់សហភាពផ្សេងទៀតដែលគ្រប់គ្រងដោយអង្គការ សន្និបាតត្រូវធ្វើការសម្រេច បន្ទាប់ពីបានស្តាប់យោបល់របស់ គណៈកម្មាធិការសម្របសម្រួលនៃអង្គការ ។

៣-

ក- ប្រទេសនីមួយៗជាសមាជិកនៃសន្និបាតមានសំលេងឆ្នោតតែមួយ ។

ខ- កូរ៉ុមនៃសន្និបាតត្រូវមានចំនួនពាក់កណ្តាលនៃប្រទេសជាសមាជិក ។

គ - ថ្វីបើមានចែងក្នុងបទប្បញ្ញត្តិនៃអនុកថាខណ្ឌ(ខ)ក៏ដោយ ក្នុងសម័យប្រជុំនីមួយៗ ប្រសិនបើចំនួនប្រទេសតំណាងមានតិចជាងមួយភាគពីរ(១/២) ប៉ុន្តែស្មើឬច្រើនជាងមួយភាគបី(១/៣)នៃប្រទេសជាសមាជិកទាំងឡាយនៃសន្និបាត សន្និបាតអាចធ្វើសេចក្តីសម្រេចបាន ប៉ុន្តែសេចក្តីសម្រេចទាំងនេះ ត្រូវយកមកអនុវត្តបានតែក្នុងករណីបានបំពេញលក្ខខណ្ឌកំណត់ដូចខាងក្រោម លើកលែងតែសេចក្តីសម្រេចនោះទាក់ទងជាមួយនីតិវិធីរបស់សន្និបាតផ្ទាល់ ។ ការិយាល័យអន្តរជាតិត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះទៅប្រទេសសមា ជិកសន្និបាតទាំងឡាយដែលគ្មានវត្តមាន និងត្រូវអញ្ជើញប្រទេសទាំងនេះឱ្យបោះឆ្នោតជាលាយលក្ខណ៍អក្សរ ឬបោះឆ្នោតអនុប្បវាទ ក្នុងរយៈពេលបី(៣)ខែ

ចាប់ពីថ្ងៃជូនដំណឹង ។ បើផុតរយៈពេលនេះ ប្រសិនបើចំនួននៃប្រទេសដែលបានបោះឆ្នោតឬបោះឆ្នោតអនុប្បវាទ ស្មើនឹងចំនួនដែលខ្វះ សម្រាប់កូរ៉ុមក្នុងសម័យប្រជុំ សេចក្តីសម្រេចនេះនឹងអាចយកមកអនុវត្តបាន ឱ្យតែបានគ្រប់សំលេងភាគច្រើនដែលត្រូវការ ។

ឃ- លើកលែងតែបទប្បញ្ញត្តិនៃមាត្រា៨(២) សេចក្តីសម្រេចនៃសន្និបាតត្រូវធ្វើឡើងដោយសំលេងពីរភាគបី(២/៣) នៃសំលេងឆ្នោតដែលបានបោះ ។

ង- អនុប្បវាទមិនត្រូវចាត់ទុកជាសំលេងឆ្នោតទេ ។

ច- ប្រតិភូម្នាក់អាចតំណាង ហើយបោះឆ្នោតបានក្នុងនាមប្រទេសតែមួយគត់ ។

ឆ- ប្រទេសទាំងឡាយនៃសហភាពពិសេសដែលមិនមែនជាសមាជិកសន្និបាតត្រូវអនុញ្ញាតឱ្យចូលរួមប្រជុំក្នុងឋានៈជាអ្នកសង្កេតការណ៍ ។

៤-

ក- សន្និបាតត្រូវប្រជុំជាសាមញ្ញរៀងរាល់ពីរឆ្នាំម្តង តាមការកោះប្រជុំរបស់អគ្គនាយក ហើយបើគ្មានករណីពិសេស ត្រូវប្រជុំក្នុងពេលនិងកន្លែងដូចគ្នានឹងមហាសន្និបាតរបស់អង្គការ ។

ខ- តាមសំណើសុំពីប្រទេសជាសមាជិកសន្និបាតចំនួនមួយភាគបួន(១/៤) សន្និបាតត្រូវប្រជុំជាវិសាមញ្ញបាន តាមការកោះប្រជុំរបស់អគ្គនាយក ។

គ- របៀបវារៈនៃការប្រជុំនីមួយៗត្រូវរៀបចំដោយអគ្គនាយក ។

៥- សន្និបាតត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

## មាត្រា៣

## [ ការិយាល័យអន្តរជាតិ ]

១-

ក- ការតម្កល់ជាអន្តរជាតិនៃគំនូរឧស្សាហកម្ម ព្រមទាំងករណីយកិច្ចទាំងឡាយដែលពាក់ព័ន្ធ ក៏ដូចជាការងាររដ្ឋបាលផ្សេងទៀតរបស់សហភាពពិសេស ត្រូវបំពេញដោយការិយាល័យអន្តរជាតិ ។

ខ- ជាពិសេស ការិយាល័យអន្តរជាតិត្រូវរៀបចំការប្រជុំ និងត្រូវបំរើការងារជាលេខាធិការដ្ឋានសម្រាប់សន្និបាត និងសម្រាប់គណៈកម្មាធិការជំនាញនិងក្រុមការងារដែលអាចនឹងបង្កើតឡើងដោយសន្និបាត ។

គ- អគ្គនាយកត្រូវជានាយកប្រតិបត្តិនៃសហភាពពិសេសនិងជាតំណាងសហភាពពិសេស ។

២- អគ្គនាយក និងបុគ្គលិកណាម្នាក់ដែលត្រូវចាត់តាំងដោយអគ្គនាយកត្រូវចូលរួមរាល់កិច្ច

ប្រជុំរបស់សន្និបាត និងរបស់គណៈកម្មាធិការជំនាញ ឬក្រុមការងារដែលនឹងអាចបង្កើតឡើងដោយសន្និបាត តែគ្មានសិទ្ធិបោះឆ្នោតទេ ។ អគ្គនាយក ឬបុគ្គលិកណាម្នាក់ដែលត្រូវចាត់តាំងដោយអគ្គនាយក គឺជាលេខាដោយស្វ័យប្រវត្តិរបស់អង្គភាពទាំងនោះ ។

៣-

ក- តាមសេចក្តីណែនាំរបស់សន្និបាត ការិយាល័យអន្តរជាតិត្រូវរៀបចំសន្និសីទកែប្រែបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង ។

ខ- ការិយាល័យអន្តរជាតិអាចប្រឹក្សាជាមួយអង្គការអន្តររដ្ឋាភិបាលនិងអង្គការអន្តរជាតិមិនមែនរដ្ឋាភិបាល ពាក់ព័ន្ធនឹងការរៀបចំសន្និសីទកែប្រែនេះ ។

គ- អគ្គនាយកនិងបុគ្គលដែលត្រូវចាត់តាំងដោយអគ្គនាយក ត្រូវចូលរួមក្នុងកិច្ចពិភាក្សាក្នុងសន្និសីទទាំងនោះ តែគ្មានសិទ្ធិបោះឆ្នោតទេ ។

៤- ការិយាល័យអន្តរជាតិត្រូវអនុវត្តការងារផ្សេងៗទៀតដែលបានប្រគល់ឱ្យ ។

## មាត្រា៤

### [ ហិរញ្ញវត្ថុ ]

១-

ក- សហភាពត្រូវមានថវិការបស់ខ្លួន ។

ខ- ថវិការបស់សហភាពពិសេសរួមមានខ្ទង់ចំនូលនិងខ្ទង់ចំណាយផ្ទាល់របស់សហភាពពិសេស វិភាគទានចំពោះថវិកាសម្រាប់ការចំណាយរួមរបស់សហភាព និងបើមានចំនួនទឹកប្រាក់ដែលមានក្នុងថវិកានៃសន្និសីទរបស់អង្គការ ។

គ- ការចំណាយដែលមិនមែនជាចំណាយផ្តាច់មុខរបស់សហភាពពិសេសប៉ុន្តែជាការចំណាយរបស់សហភាពមួយឬច្រើនផ្សេងទៀត ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អង្គការ ត្រូវចាត់ទុកជាចំណាយរួមរបស់សហភាព ។ ចំណែកនៃសហភាពពិសេសក្នុងខ្ទង់ចំណាយរួមនេះ ត្រូវសមាមាត្រនឹងផលប្រយោជន៍ដែលសហភាពពិសេសទទួលបានក្នុងចំណាយនោះ ។

២- ថវិការបស់សហភាពពិសេសត្រូវបង្កើតឡើងដោយផ្អែកលើតម្រូវការសម្របសម្រួលជាមួយថវិកានៃសហភាពផ្សេងទៀតដែលគ្រប់គ្រងដោយអង្គការ ។

៣- ថវិការបស់សហភាពពិសេសទទួលបានពីប្រភពនានាដូចខាងក្រោម:

(i) កម្រៃនៃការតម្កល់ជាអន្តរជាតិនិងកម្រៃផ្សេងៗទៀតព្រមទាំងថ្លៃឈ្នួលសេវាកម្មផ្សេងៗទៀតដែលផ្តល់ឱ្យដោយការិយាល័យអន្តរជាតិទាក់ទងនឹងសហភាពពិសេស

(ii) ការលក់ ឬលាភការ ពីការបោះពុម្ពផ្សាយរបស់ការិយាល័យអន្តរជាតិពាក់ព័ន្ធនឹងសហភាពពិសេស

(iii) អំណោយ អច្ច័យទាន និងឧបត្ថម្ភធន

(iv) ការជួល ការប្រាក់ និងចំណូលផ្សេងៗទៀត

៤-

ក- បរិមាណនៃកម្រៃដូចមានចែងក្នុងកថាខណ្ឌ(៣)(i) ត្រូវកំណត់ដោយសន្និបាតតាមសំណើរបស់អគ្គនាយក ។

ខ- បរិមាណនៃកម្រៃនេះ ត្រូវតែកំណត់បែបនេះដើម្បីឱ្យ ចំណូលរបស់សហភាពពិសេសដែលបានពីកម្រៃនិងប្រភពផ្សេងៗទៀត យ៉ាងហោចណាស់ត្រូវតែគ្រប់គ្រាន់ដើម្បីគ្រប់គ្រងការចំណាយរបស់ការិយាល័យអន្តរជាតិពាក់ព័ន្ធនឹងសហភាពពិសេស ។

គ- ប្រសិនបើថវិកាមិនត្រូវបានអនុម័តមុនការចាប់ផ្តើមនៃរយៈពេលហិរញ្ញវត្ថុថ្មីទេ ថវិកានេះ ត្រូវតែមានកម្រិតស្មើគ្នាទៅនឹងថវិកាឆ្នាំមុន ដូចមានចែងក្នុងបទបញ្ជាហិរញ្ញវត្ថុ ។

៥- លើកលែងបទប្បញ្ញត្តិនៃកថាខណ្ឌ(៤)(ក) បរិមាណនៃកម្រៃនិងថ្លៃឈ្នួលសេវាកម្មផ្សេងៗដែលបានផ្តល់ឱ្យដោយការិយាល័យអន្តរជាតិពាក់ព័ន្ធនឹងហាភាពពិសេស ត្រូវធ្វើឡើង និងត្រូវរាយការណ៍ជូនសន្និបាតដោយអគ្គនាយក ។

៦-

ក- សហភាពពិសេសត្រូវមានមូលនិធិទុនបង្វិលដែលត្រូវបង្កើតឡើងដោយចំណូលដែលលើស និង ប្រសិនបើចំនួនដែលលើសនេះមិនគ្រប់គ្រាន់ ដោយការបង់ប្រាក់សរុបរួមតែមួយពីប្រទេសនីមួយៗនៃសហភាពពិសេស ។ ប្រសិនបើមូលនិធិនេះ មិនគ្រប់គ្រាន់សន្និបាតអាចសម្រេចបង្កើនមូលនិធិនេះបាន ។

ខ- បរិមាណនៃការបង់កម្រៃដំបូងរបស់ប្រទេសនីមួយៗចំពោះមូលនិធិនេះ ឬចំពោះការចូលរួមរបស់ខ្លួនក្នុងការបង្កើនមូលនិធិ ត្រូវសមាមាត្រនឹងវិភាគទាននៃប្រទេសនេះដែលជាសមាជិកនៃសហភាពទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ចំពោះថវិកានៃសហភាពនេះសម្រាប់ឆ្នាំនៃការបង្កើតមូលនិធិនេះ ឬសម្រាប់ឆ្នាំនៃការសម្រេចបង្កើនមូលនិធិ។

គ- សមាត្រ និងរយៈនៃការបង់ប្រាក់ត្រូវកំណត់ដោយសន្និបាតតាមសំណើរបស់អគ្គនាយក និងបន្ទាប់ពីបានស្តាប់យោបល់របស់គណៈកម្មាធិការសម្របសម្រួលនៃអង្គការ ។

៧ -

ក- នៅក្នុងកិច្ចព្រមព្រៀងទីស្នាក់ការ ដែលបានចុះជាមួយប្រទេសដែលអង្គការដាក់

ទីស្នាក់ការនៅលើទឹកដីប្រទេសនោះ ត្រូវចែងថា នៅពេលណាដែលមូលនិធិទុនបង្វិលមិនគ្រប់គ្រាន់ ប្រទេសនេះត្រូវបង់ប្រាក់ជាមុន ។ ចំនួននៃប្រាក់បង់ជាមុន និងលក្ខខណ្ឌនៃការបង់ជាមុន ត្រូវកំណត់ដោយកិច្ចព្រមព្រៀងដោយឡែកពីគ្នារវាងប្រទេសនេះនិងអង្គការតាមករណីនីមួយៗ ។

ខ- ប្រទេសដូចមានចែងក្នុងអនុកថាខណ្ឌ(ក) និងអង្គការ ត្រូវមានសិទ្ធិបដិសេធកាតព្វកិច្ចបង់ប្រាក់ជាមុន ដោយសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ។ ការបដិសេធនេះ ត្រូវមានអានុភាពក្នុងរយៈពេលបី(៣)ឆ្នាំ បន្ទាប់ពីបំណាច់ឆ្នាំនៃការជូនដំណឹង ។

៨- សវនកម្មគណនី ត្រូវធ្វើឡើងដោយប្រទេសមួយឬច្រើននៃសហភាពពិសេស ឬដោយសវនករខាងក្រៅ ដូចមានចែងក្នុងបទបញ្ញាហិរញ្ញវត្ថុ ។ សវនករ ត្រូវចាត់តាំងដោយសន្និបាត ដោយមានការយល់ព្រមពីសវនករនេះ ។

## មាត្រា៥

**[ វិសោធនកម្មមាត្រា២ ដល់មាត្រា៥ ]**

១- សំណើសុំវិសោធនកម្មនៃច្បាប់បំពេញ បន្ថែមនេះអាចត្រូវផ្តួចផ្តើមគំនិតដោយប្រទេសសមាជិកណាមួយនៃសន្និបាត ឬដោយអគ្គនាយក ។ សំណើនេះត្រូវជូនដំណឹងដោយអគ្គនាយកទៅកាន់ប្រទេសដែលជាសមាជិកសន្និបាត យ៉ាងហោចណាស់ក្នុងរយៈពេលប្រាំមួយ(៦) ខែ មុនពេលសន្និបាតលើកសំណើនេះមកពិចារណា ។

២- វិសោធនកម្មដូចមានចែងក្នុងកថាខណ្ឌ(១) ត្រូវអនុម័តដោយសន្និបាត ។ ការអនុម័តនេះទាមទារឱ្យមានសំលេងឆ្នោតបីភាគបួន(៣/៤) តែវិសោធនកម្មមាត្រា២ និងកថាខណ្ឌនេះ ទាមទារឱ្យមានសំលេងឆ្នោតបួនភាគប្រាំ(៤/៥) ។

៣- វិសោធនកម្មណាមួយដូចមានចែងក្នុងកថាខណ្ឌ(១) ត្រូវចូលជាធរមានក្នុងរយៈពេលមួយ(១)ខែ បន្ទាប់ពីអគ្គនាយកទទួលបានសេក្តីជូនដំណឹងនៃការយល់ព្រម ដែលបានធ្វើឡើងស្របតាមរដ្ឋធម្មនុញ្ញនៃប្រទេសរៀងៗខ្លួន ដោយប្រទេសបីភាគបួន(៣/៤) ដែលជាសមាជិកសន្និបាតហើយមានវត្តមាននៅពេលអនុម័តវិសោធនកម្មនេះ ។ វិសោធនកម្មណាមួយដែលត្រូវបានទទួលយក មានអានុភាពចងប្រទេសទាំងឡាយដែលជាសមាជិកសន្និបាត នៅពេលដែលវិសោធនកម្មទាំងនោះចូលជាធរមាន ឬក្លាយជាសមាជិកនាពេលក្រោយ ។

## មាត្រា៦

## [ វិសោធនកម្មច្បាប់ឆ្នាំ១៩៣៤ និងច្បាប់បន្ថែមឆ្នាំ១៩៦១ ]

១-

ក- ការយោងក្នុងច្បាប់ឆ្នាំ១៩៣៤ ដល់ " ការិយាល័យអន្តជាតិកម្មសិទ្ធិឧស្សាហកម្មទីក្រុងប៊ែន " " ការិយាល័យអន្តរជាតិទីក្រុងប៊ែន " ឬក៏ " ការិយាល័យអន្តរជាតិ " ត្រូវបកស្រាយថាជាការយោងដល់ ការិយាល័យអន្តរជាតិដូចមានចែងក្នុងមាត្រា១ នៃច្បាប់បំពេញបន្ថែមនេះ ។

ខ- មាត្រា ១៥ នៃច្បាប់ឆ្នាំ១៩៣៤ ត្រូវបាននិរាករណ៍ ។

គ- វិសោធនកម្មណាមួយនៃបទបញ្ញាដូចមានចែងក្នុងមាត្រា២០ នៃច្បាប់ឆ្នាំ ១៩៣៤ ត្រូវធ្វើឡើងស្របតាមនីតិវិធីដែលបានកំណត់តាមមាត្រា២(២)(ក)(iii) និងមាត្រា២(៣)(ឃ) ។

ឃ-ក្នុងមាត្រា២១នៃច្បាប់ឆ្នាំ១៩៣៤ ពាក្យ " បានកែប្រែក្នុងឆ្នាំ១៩២៨" ត្រូវបានជំនួសដោយពាក្យថា " ស្តីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រនិងសិល្បៈ " វិញ ។

ង- ការយោងក្នុងមាត្រា២២នៃច្បាប់ឆ្នាំ១៩៣៤ដល់មាត្រា១៦ ១៦ស្ទួន និងមាត្រា១៧ស្ទួន នៃ " អនុសញ្ញាទូទៅ " ត្រូវបកស្រាយ ថាជាការយោងដល់បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ទីក្រុងស្តុកខុល នៃអនុសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ដែលទាក់ទងនឹងមាត្រា១៦ មាត្រា១៦ស្ទួន និងមាត្រា១៧ស្ទួននៃច្បាប់មុនៗ របស់អនុសញ្ញា ទីក្រុងប៉ារីសក្នុងច្បាប់ស្តុកខុលនេះ ។

២-

ក- ការផ្លាស់ប្តូរណាមួយនៃកម្រៃដូចមានចែងក្នុងមាត្រា៣ នៃច្បាប់បន្ថែមឆ្នាំ ១៩៦១ ត្រូវធ្វើឡើងស្របតាមនីតិវិធីដែលបានកំណត់តាមមាត្រា ២(២)(ក)(iii) និង ២(៣)(ឃ) ។

ខ- មាត្រា៤(១)នៃច្បាប់បន្ថែមឆ្នាំ១៩៦១ និងពាក្យថា " នៅពេលដែលមូលនិធិបំរុងបានកើនដល់ចំនួននេះ" ក្នុងមាត្រា៤(២) ត្រូវនិរាករណ៍ ។

គ- ការយោងក្នុងមាត្រា៦(២) នៃច្បាប់បន្ថែមឆ្នាំ១៩៦១ ដល់ មាត្រា១៦ និង១៦ស្ទួន នៃអនុសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្មត្រូវបកស្រាយថា ជាការយោងដល់ បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ទីក្រុងស្តុកខុលនៃអនុសញ្ញានេះ ដែលទាក់ទងនឹងមាត្រា១៦ និង១៦ស្ទួននៃច្បាប់មុនៗរបស់អនុសញ្ញាទីក្រុងប៉ារីស ក្នុងច្បាប់ទីក្រុងស្តុកហូម ។

ឃ- ការយោងក្នុងកថាខណ្ឌ៧(១) និងកថាខណ្ឌ៧(៣) នៃច្បាប់បន្ថែមឆ្នាំ១៩៦១ ដល់ រដ្ឋាភិបាលនៃសហព័ន្ធស្វីស ត្រូវបកស្រាយថាជាការយោងដល់ អគ្គនាយក ។

## មាត្រា៧
## [វិសោធនកម្មច្បាប់ឆ្នាំ១៩៦០]

១- ការយោងក្នុងច្បាប់ឆ្នាំ១៩៦០ ដល់ "ការិយាល័យនៃសហភាពអន្តរជាតិស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម" ឬ "ការិយាល័យអន្តរជាតិ" ត្រូវបកស្រាយថាជាការយោងដល់ការិយាល័យអន្តរជាតិដូចមានចែងក្នុងមាត្រា១ នៃច្បាប់ចំពេញបន្ថែមនេះ ។
២- មាត្រា១៩ ២០ ២១ និងមាត្រា២២ នៃច្បាប់ឆ្នាំ១៩៦០ ត្រូវនិរាករណ៍ ។
៣-ការយោងក្នុងច្បាប់ឆ្នាំ១៩៦០ដល់ រដ្ឋាភិបាលនៃសហព័ន្ធស្វីស ត្រូវបកស្រាយថាជាការយោងដល់ អគ្គនាយក ។
៤- ក្នុងមាត្រា២៩ នៃច្បាប់ឆ្នាំ១៩៦០ ពាក្យ "ព្រឹត្តិបត្រ" (កថាខណ្ឌ២៩(១)) និងពាក្យ " នៃគណៈ កម្មាធិការគំនូរអន្តរជាតិឬ " ( កថាខណ្ឌ២៩(២)) ត្រូវបានលុបចោល ។

## មាត្រា៨
## [ ការផ្តល់សច្ចាប័ន និងការចូលជាសមាជិកនៃច្បាប់បំពេញបន្ថែម ]

១-

ក- មុនថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៦៨ ប្រទេសទាំងឡាយដែលបានផ្តល់សច្ចាប័នច្បាប់ឆ្នាំ១៩៣៤ ឬច្បាប់ឆ្នាំ១៩៦០ និងប្រទេសទាំងឡាយដែលបានចូលជាសមាជិកយ៉ាងហោចណាស់នៃច្បាប់មួយក្នុងចំណោមច្បាប់ទាំងពីរនេះ អាចចុះហត្ថលេខានិងផ្តល់សច្ចាប័នលើច្បាប់បំពេញបន្ថែមនេះ ឬអាចចូលជាសមាជិកនៃច្បាប់បំពេញបន្ថែមនេះ ។

ខ- ការផ្តល់សច្ចាប័នឬការចូលជាសមាជិកនៃច្បាប់បំពេញបន្ថែមនេះដោយប្រទេសដែលបានចងភ្ជាប់ដោយច្បាប់ឆ្នាំ១៩៣៤ ដែលមិនបានចងភ្ជាប់ផងដែរដោយច្បាប់បន្ថែមឆ្នាំ១៩៦១ តម្រូវឱ្យផ្តល់សច្ចាប័ន ឬចូលជាសមាជិកនៃច្បាប់បន្ថែមឆ្នាំ១៩៦១ ជាស្វ័យប្រវត្តិ ។

២- លិខិតតុបករណ៍នៃការផ្តល់សច្ចាប័ននិងការចូលជាសមាជិកត្រូវតម្កល់ជូនអគ្គនាយក ។

## មាត្រា៩
## [ ការចូលជាធរមាននៃច្បាប់បំពេញបន្ថែម]

១- ច្បាប់បំពេញបន្ថែមនេះត្រូវចូលជាធរមានក្នុងរយៈបី(៣)ខែ បន្ទាប់ពីការតម្កល់លិខិតតុបករណ៍នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិកទីប្រាំ ចំពោះប្រាំប្រទេសដំបូងដែលបាន

តម្កល់លិខិតតុបករណ៍នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិករបស់ខ្លួន ។
២- ចំពោះប្រទេសណាមួយផ្សេងទៀត ច្បាប់បំពេញបន្ថែមនេះ ត្រូវចូលជាធរមានក្នុងរយៈពេលបី(៣)ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងអំពីការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកដោយអគ្គនាយក លើកលែងតែកាលបរិច្ឆេទបន្ទាប់បានបង្ហាញនៅក្នុងលិខិតតុបករណ៍នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិក ។ ក្នុងករណីក្រោយនេះ ច្បាប់បំពេញបន្ថែមនេះត្រូវចូលជាធរមានចំពោះប្រទេសនោះ តាមកាលបរិច្ឆេទដែលបានកំណត់ ។

## មាត្រា១០

## [ កាទទួលយកជាស្វ័យប្រវត្តិនូវបទប្បញ្ញត្តិមួយចំនួនដោយប្រទេសមួយចំនួន]

១- លើកលែងបទប្បញ្ញត្តិនៃមាត្រា៨និងកថាខណ្ឌដូចខាងក្រោម ប្រទេសណាមួយដែលមិនបានផ្តល់សច្ចាប័នឬចូលជាសមាជិកច្បាប់ឆ្នាំ១៩៣៤ ត្រូវចងភ្ជាប់ដោយច្បាប់បន្ថែមឆ្នាំ១៩៦១ និងដោយមាត្រា១ដល់មាត្រា៦នៃច្បាប់បំពេញបន្ថែមនេះ ចាប់ពីកាលបរិច្ឆេទនៃការចូលជាសមាជិករបស់ខ្លួនទៅនឹងច្បាប់ឆ្នាំ១៩៣៤ដែលចូលជាធរមាន ឱ្យតែតាមកាលបរិច្ឆេទនេះ ប្រសិនបើ ច្បាប់បំពេញបន្ថែមនេះមិនទាន់ចូលជាធរមានទៅតាមមាត្រា៩(១) បន្ទាប់មកប្រទេសនេះនឹងត្រូវចងភ្ជាប់ដោយមាត្រាទាំងនេះ នៃច្បាប់បំពេញបន្ថែមតែចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃច្បាប់បំពេញបន្ថែម តាមមាត្រា៩(១)តែប៉ុណ្ណោះ ។
២-លើកលែងបទប្បញ្ញត្តិនៃមាត្រា៨និងកថាខណ្ឌមុន ប្រទេសណាមួយដែលមិនបានផ្តល់សច្ចាប័នឬចូលជាសមាជិកច្បាប់ឆ្នាំ១៩៦០ ត្រូវចងភ្ជាប់ដោយមាត្រា១ដល់មាត្រា៧នៃច្បាប់បំពេញបន្ថែមនេះ ចាប់ពីកាលបរិច្ឆេទនៃការផ្តល់សច្ចាប័នឬចូលជាសមាជិករបស់ខ្លួន ទៅនឹងច្បាប់ឆ្នាំ១៩៦០ដែលចូលជាធរមាន ឱ្យតែតាមកាលបរិច្ឆេទនេះ ប្រសិនបើច្បាប់បំពេញបន្ថែមនេះមិនទាន់ចូលជាធរមានទៅតាមមាត្រា៩(១) បន្ទាប់មកប្រទេសនេះនឹងត្រូវចងភ្ជាប់ដោយមាត្រាទាំងនេះនៃច្បាប់បំពេញបន្ថែម តែចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃច្បាប់បំពេញបន្ថែមតាមមាត្រា៩(១)តែប៉ុណ្ណោះ ។

## មាត្រា១១

## [ ការចុះហត្ថលេខា។ល។នៃច្បាប់បំពេញបន្ថែម ]

១-

ក- ច្បាប់បន្ថែមនេះត្រូវចុះហត្ថលេខាជាឯកសារតែមួយ ជាភាសាបារាំង និងត្រូវតម្កល់ជូនរដ្ឋាភិបាលនៃប្រទេសស៊ុយអ៊ែត ។

ខ- អត្ថបទផ្លូវការនានានឹងត្រូវធ្វើឡើងដោយអគ្គនាយក បន្ទាប់ពីពិភាក្សាជាមួយនឹងរដ្ឋាភិបាលដែលពាក់ព័ន្ធ ជាភាសាផ្សេងៗទៀតដែលសន្និបាតអាចកំណត់ ។

២- ច្បាប់បំពេញបន្ថែមនេះនៅតែបើកចំហសម្រាប់ការចុះហត្ថលេខា នៅទីក្រុងស្តុកខុល រហូតដល់ថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៦៨ ។

៣- អគ្គនាយកត្រូវបញ្ជូនច្បាប់ចម្លងពីរច្បាប់ នៃអត្ថបទដែលបានចុះហត្ថលេខានៃច្បាប់បំពេញបន្ថែមនេះ ដែលបញ្ជាក់ថាត្រឹមត្រូវដោយរដ្ឋាភិបាលប្រទេសស៊ុយអ៊ែតទៅរដ្ឋាភិបាលនៃប្រទេសទាំងអស់ក្នុងសហភាពពិសេស និងទៅរដ្ឋាភិបាលនៃប្រទេសផ្សេងទៀតតាមការស្នើសុំ ។

៤- អគ្គនាយកត្រូវចុះបញ្ជីច្បាប់បំពេញបន្ថែមនេះ នៅលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ ។

៥- អគ្គនាយកត្រូវជូនដំណឹងដល់រដ្ឋាភិបាលនៃប្រទេសទាំងអស់ក្នុងសហភាពពិសេសអំពីការចុះហត្ថលេខា ការតម្កល់លិខិតតុបករណ៍នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិក ការចូលជាធរមាន និងសេចក្តីជូនដំណឹងផ្សេងទៀតទាំងអស់ដែលពាក់ព័ន្ធ ។

## មាត្រា១២
## [អន្តរប្បញ្ញត្តិ]

រហូតដល់អគ្គនាយកដំបូងចូលកាន់តំណែង ការយោងក្នុងច្បាប់បំពេញបន្ថែមនេះ ដល់ការិយាល័យអន្តរជាតិនៃអង្គការ ឬដល់អគ្គនាយក ត្រូវបកស្រាយថាជាការយោងដល់ការិយាល័យនៃសហភាពដែលបានបង្កើតឡើងដោយអនុសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ឬនាយកការិយាល័យ តាមករណីនីមួយៗ ។